# សុន្ទរកថា
# ឯកឧត្តម ខឹម វិសុទ្ធ ឧបនាយករដ្ឋមន្ត្រីប្រចាំការ
# រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាអ្នកច្បាប់ និងជា
# ប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
## ថ្លែងក្នុង
## សិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំ
## ស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់
## និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត

រាជធានីភ្នំពេញ ថ្ងៃព្រហស្បតិ៍ ១១កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ត្រូវនឹងថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤

- *ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី*
- *ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល*
- *ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ ទីប្រឹក្សា សមាជិក សមាជិកា នៃក្រុមប្រឹក្សាអ្នកច្បាប់*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី*
- *ប្អូនៗ និងក្មួយៗ ជានិស្សិតនៅតាមសាកលវិទ្យាល័យនានា!*

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានមកចូលរួមជាអធិបតីក្នុងសិក្ខាសាលាផ្សព្វផ្សាយ **អនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត** នាពេលនេះ។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ដែលអញ្ជើញមកពីគ្រប់ក្រសួងស្ថាប័ននានា ព្រមទាំងប្អូនៗ និងក្មួយៗជានិស្សិត ដែលបានចូលរួមក្នុងសិក្ខាសាលាផ្សព្វផ្សាយដ៏សំខាន់នេះ។

គោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត កម្រាស់ជិត ២០០ទំព័រ ដែលត្រូវបានដាក់ឱ្យអនុវត្តដោយអនុក្រឹត្យលេខ ១៧០ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ បន្ទាប់ពីទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គ កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ គឺជាការធ្វើបច្ចុប្បន្នកម្ម កែសម្រួល និងបំពេញបន្ថែមលើគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតឆ្នាំ២០១៣ ហើយទីស្តីការគណៈរដ្ឋមន្ត្រីបានចាប់ផ្តើមធ្វើកិច្ចការនេះ ចាប់តាំងពីឆ្នាំ២០១៩ និងបានបញ្ចប់ជាស្ថាពរនៅក្នុងខែមេសា ឆ្នាំ២០២៤ ដោយមានគោលបំណង និងសារៈ ដូចក្នុងរបាយការណ៍លើកឡើងរបស់ឯកឧត្តមបណ្ឌិត **ស៊ា ម៉ៅ** អម្បាញ់មិញ។

គោលការណ៍ណែនាំនេះ មានគោលបំណងលើកកម្ពស់អនុលោមភាព សង្គតិភាព គុណភាព ប្រសិទ្ធភាព និងធានាឱ្យមានការឯកភាព ក្នុងការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងទៀតនៅព្រះរាជាណាចក្រកម្ពុជា សំដៅឆ្លើយតបទៅនឹងចក្ខុវិស័យ និងសេចក្តីត្រូវការនានារបស់សង្គមជាតិ ដូចមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ដែលមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ជាប្រមុខ។ គោលការណ៍ណែនាំនេះ ត្រូវបានបែងចែកជាផ្នែកទៅតាមខ្លឹមសារសំខាន់ៗ ដែលមានសេចក្តីណែនាំលម្អិត ក្នុងការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងទៀត ដើម្បីជៀសវាងភាពមិនស៊ីសង្វាក់គ្នា ឬជាន់សមត្ថកិច្ចគ្នា ឬផលវិបាកមិនល្អទៅដល់បុគ្គល ធុរកិច្ច និងសង្គម។ ក្នុងន័យនេះ ខ្ញុំមានជំនឿយ៉ាងមុតមាំថា គោលការណែនាំនេះ នឹងក្លាយឧបករណ៍តម្រង់ទិស ដើម្បីធានាឱ្យមានការឯកភាព និងសង្គតិភាពនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលត្រូវរៀបចំឡើងដោយក្រសួង ស្ថាប័ន ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងវិស័យនៃការទទួលខុសត្រូវរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យរបស់កម្ពុជា ក្នុងការសម្រេចបានជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។

ខ្ញុំសូមគូសបញ្ជាក់ជូនថា គោលការណ៍ណែនាំនេះ ត្រូវបានរៀបចំឡើងដោយឈរលើទស្សនវិជ្ជានីតិរដ្ឋ (Rule of Law) ដែលរដ្ឋនីមួយៗត្រូវតែមានក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់ និងគ្រប់ជ្រុងជ្រោយ ដែលធានាបាននូវសិទ្ធិ សេរីភាព កម្មសិទ្ធិឯកជន ក៏ដូចជាការការពារប្រយោជន៍សាធារណៈ ការពារបាននូវតម្លៃនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សមភាព និងយុត្តិធម៌នៅចំពោះមុខច្បាប់ និងធ្វើឱ្យការគ្រប់គ្រងវិស័យសេដ្ឋកិច្ច សង្គមកិច្ច ប្រព្រឹត្តទៅដោយរលូននិងមានប្រសិទ្ធភាព។

## *ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

គោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ដែលត្រូវបានផ្សព្វផ្សាយជាផ្លូវការនាពេលនេះ គឺជាផ្នែកតូចមួយស្ថិតនៅក្នុងក្របខ័ណ្ឌនៃការកែទម្រង់ច្បាប់ ហើយក៏ជាការចាប់ផ្តើមដ៏សំខាន់មួយ នៅក្នុងដំណើរដ៏វែងឆ្ងាយនៃការកែទម្រង់ច្បាប់នៅកម្ពុជា ដែលមានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ជាយន្តការដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តការងារកែទម្រង់ច្បាប់។ នៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ ខ្ញុំបានលើកឡើងនូវទស្សនៈនិង គោលការណ៍មួយចំនួនពាក់ព័ន្ធនឹងទស្សនវិជ្ជារួមនិងគោលដៅរបស់កម្ពុជាក្នុងការកែទម្រង់ច្បាប់ជូន **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។ ថ្ងៃនេះជាថ្មីម្តងទៀត ក្នុងនាមជាប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ខ្ញុំសូមឆ្លៀតក្នុងឱកាសនេះ ដើម្បីចែករំលែកនូវទស្សនៈនិងគោលការណ៍មួយចំនួនពាក់ព័ន្ធនឹងទស្សនវិជ្ជារួម និងគោលដៅរបស់កម្ពុជាក្នុងការកែទម្រង់ច្បាប់។

ពិតណាស់ កម្ពុជាមានការឯកភាពខាងទស្សនៈនយោបាយក្នុងការប្រកាន់យកនីតិរដ្ឋ ឬការគ្រប់គ្រងរដ្ឋដោយយកច្បាប់ជាធំ(Rule of law) ដែលបានចារឹកនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដោយប្រកាន់ យកនូវគុណតម្លៃនៃប្រព័ន្ធនយោបាយលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស និងសិទ្ធិបុគ្គល ព្រមទាំងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។ ប្រវត្តិសាស្ត្រច្បាប់របស់ខ្មែរ បានចង្អុលបង្ហាញថាប្រទេសខ្មែរមានច្បាប់ ឬក្បួនសម្រាប់គ្រប់គ្រងរដ្ឋ មានចំណែកធំកើតចេញពីលទ្ធិសាសនា ដូចជា ព្រហ្មញ្ញសាសនា លទ្ធិទេវរាជ

ពុទ្ធសាសនាមហាយាន ជាដើម និង ក្រោយមកការទទួលឥទ្ធិពលព្រះពុទ្ធសាសនាថេរវាទ ឬហិនយាន និងរបប គ្រប់គ្រងបែបបារាំង ជាដើម។ល។ ក្នុងន័យនេះ ការគ្រប់គ្រងរដ្ឋរបស់កម្ពុជាមានវិធាននិងមានច្បាប់ពីយូរយារណាស់ហើយ ដែលផ្សារភ្ជាប់ជាមួយ សាសនា វប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណី។

ជាមួយគ្នានេះ ទស្សនវិជ្ជាអំពីនីតិរដ្ឋ ពុំមែនជារឿងថ្មីនោះទេ នៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។ ទស្សនាទានអំពីនីតិរដ្ឋមានឃើញអនុវត្តនៅប្រទេសចិនជំនាន់បុរាណ (រាជវង្សឈីង) ហៅថា ទ្រឹស្តី Legalism មានន័យថា ច្បាប់គឺច្បាប់ ដែលគ្រប់គ្នាត្រូវតែគោរពដូចៗគ្នា។ នៅអឺរ៉ុបនៅក្នុងសម័យកាលចក្រភពរ៉ូមនិងក្រិច គឺចាប់ផ្តើមពីការអនុវត្តតាម Rule by law ទេ ប៉ុន្តែក្រោយមកសម័យរ៉ឺណេសង់ (Renaissance) ទើបចាប់កកើតឡើងនូវទស្សនាទានអំពីនីតិរដ្ឋនេះ ដើម្បីដោះស្រាយការដណ្តើមអំណាច រវាងវណ្ណៈ ក្រុមសាសនា ឬ ស្ថាប័នជាតិសំខាន់ៗ។ ដូចនេះ នីតិរដ្ឋកើតចេញពីការឯកភាពគ្នាលើការកំណត់នូវវិធាននានា (Rules based) ដែលមានលក្ខណៈច្បាស់លាស់ ដោយដាក់ចេញនូវគុណតម្លៃ(Value) ទៅក្នុងវិធានទាំងនោះ ឱ្យទៅជាច្បាប់ សម្រាប់ទាំងអស់គ្នាគោរពតាម ហើយគ្មានអ្នកណាមានសិទ្ធិលើសអ្នកណាចំពោះមុខច្បាប់ឡើយ គឺត្រូវតែស្មើគ្នា ចំពោះមុខច្បាប់ ហើយនៅក្រោមច្បាប់ទាំងអស់គ្នា។ ដូច្នេះ បើដាក់ច្បាប់នៅលើមនុស្ស ច្បាប់នោះត្រូវតែល្អ និងត្រូវមានប្រយោជន៍ ពិសេសត្រូវសក្តិសមនឹងតថភាពសង្គមជាក់ស្តែង និងត្រូវបម្រើឱ្យការការពារជាតិ ការកសាងជាតិ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ លើសពីនេះ អភិក្រមនៃការបង្កើតច្បាប់ គឺច្បាប់បង្កើតមកដើម្បីដោះស្រាយបញ្ហារបស់មនុស្សនិងសង្គម ពុំមែនជាការបង្កើតបញ្ហាបន្ថែម ឬការបង្កើតបន្ទុកនោះទេ។ ឧទាហរណ៍ ក្នុងសេដ្ឋកិច្ចទីផ្សារ ការបង្កើតច្បាប់ គឺដើម្បីជួយឱ្យយន្តការទីផ្សារ (Invisible hand) មានប្រសិទ្ធភាពសេដ្ឋកិច្ច, ជំរុញផលិតភាពការងារ និងនវានុវត្តន៍ (Innovation) ព្រមទាំងជួយឱ្យមនុស្សខិតខំប្រឹងប្រែង ហើយបញ្ចេញអស់សមត្ថភាពរៀងៗខ្លួន ទាំងសមត្ថភាពមានពីធម្មជាតិ ទាំងការបង្កើនសមត្ថភាពតាមរយៈការខិតខំរៀនសូត្រ ដើម្បីឱ្យពូកែនិងមានភាពជោគជ័យ ដោយផ្អែកលើគោលការណ៍ Fair Level Playing Field ឬការប្រកួតប្រជែងដោយស្មើភាព(Fair competition) និងត្រូវមានលក្ខខណ្ឌនិងវិធានដទៃ ទៀត ដើម្បីផ្តល់ឱកាសស្មើគ្នា (Equal opportunities) និងធានាឱ្យសង្គមរីកចម្រើនទៅមុខ (Progress)។

ដូចនេះ ការប្រកាន់ខ្ជាប់នូវទស្សនវិជ្ជានីតិរដ្ឋរបស់កម្ពុជា គឺត្រូវឱ្យស្របតាមបរិការណ៍កម្ពុជា ដែលត្រូវបង្កប់នូវគុណតម្លៃល្អៗ និងមានប្រយោជន៍របស់សង្គមជាតិយើង ក្នុងនោះមានទាំងគុណតម្លៃផ្នែកសីលធម៌ (Ethic) និយាមសង្គម (Social norm) ប្រពៃណី (Tradition) និងទំនៀមទម្លាប់ (Custom) ផងដែរ។ សង្គមជាតិយើងត្រូវការទាំងទស្សនៈនីតិរដ្ឋនិងទស្សនៈសីលធម៌ ដើម្បីបំពេញឱ្យគ្នាទៅវិញទៅមក។ ក៏ប៉ុន្តែប្រសិនបើយើងពិនិត្យលើការណ៍ជាក់ស្តែង បន្ទាប់ពីដំណាក់កាលនៃការផ្សះផ្សានិងបង្រួបបង្រួមជាតិ មូលដ្ឋាននៃទស្សនវិជ្ជានីតិរដ្ឋ ដែលយើងទទួលយកសម្រាប់គ្រប់គ្រងរដ្ឋ ក៏ដូចជាសម្រាប់ការកសាងប្រព័ន្ធច្បាប់របស់កម្ពុជានៅមិនទាន់រឹងមាំនៅឡើយ ព្រោះម្យ៉ាងពេលនោះ យើងក៏ពុំទាន់មានសមត្ថភាពរៀបចំច្បាប់ដោយខ្លួនឯងបាននៅឡើយ ដោយសារតែទើបងើបចេញពីសង្គ្រាមបង្ហូរឈាម ហើយម៉្យាងទៀត នីតិរដ្ឋ ក៏ជាទស្សនាទានថ្មីសម្រាប់សង្គមកម្ពុជាយើងដែរ ដូចជាលទ្ធិប្រជាធិបតេយ្យ ហើយត្រូវបានគួបផ្សំជាមួយផ្នត់គំនិតខ្មែរ។ ដូចនេះ កម្ពុជាគ្មានជម្រើសអ្វីផ្សេងក្រៅតែពីត្រូវពឹងបរទេសមកជួយកសាង នូវប្រព័ន្ធច្បាប់ ដើម្បីឱ្យរដ្ឋមានដំណើរការទៅមុខឱ្យរួចមួយគ្រាៗសិន សម្រាប់បម្រើឱ្យការស្តារ ការកសាង និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ ប្រការនេះបានធ្វើឱ្យកម្ពុជាទទួលបាននូវប្រព័ន្ធច្បាប់ចម្រុះមួយរួមបញ្ចូលគ្នាទៅ តាមប្រព័ន្ធច្បាប់របស់ប្រទេសម្ចាស់ផ្ត

ល់ជំនួយឬជំនាញការបរទេសដែលដៃគូបានបញ្ជូនមក ឱ្យជួយរៀបចំ ដូចជា ប្រព័ន្ធច្បាប់Civil Law និង Common Law ជាដើម។ល។ ព្រមទាំងប្រព័ន្ធច្បាប់ខ្មែរ ឬ ទំនៀមដែលមានពីមុនមកស្រាប់។ **យើងសង្កេតឃើញថា ច្បាប់ដែលត្រូវបានរៀបចំឡើងតាមរយៈជំនួយបច្ចេកទេសឬជំនាញការ បរទេសពីសំណាក់ដៃគូ ឬ ពីប្រទេសដែលមានប្រព័ន្ធច្បាប់ផ្សេងៗពីគ្នាទាំងនោះ គឺមានចំណុចខ្លះក្នុងកម្រិតណាមួយបុកគ្នា និងមានចំណុចខ្លះទៀតមិនស្របតាមស្ថានភាពជាក់ស្តែងរបស់កម្ពុជាតែម្តង ដោយសារខ្វះការធ្វើការបន្សុី (Reconcile) ប្រកពច្បាប់ឱ្យមានចរិតលក្ខណៈជារបស់ខ្មែរ។**

ដូច្នេះ ក្នុងវដ្តថ្មីនេះ យើងគួរផ្លាស់ប្តូរពីអភិក្រមដែលហៅថា ដើម្បីឱ្យតែរស់ឬដើម្បីឱ្យរួចតែមួយគ្រាៗ សិននេះ មកជា ត្រូវមានទស្សនវិស័យវែងឆ្ងាយ មានទស្សនវិជ្ជាត្រឹមត្រូវនៃការកសាងនីតិរដ្ឋ និងត្រូវបង្កើតគោលការណ៍ច្បាស់លាស់ នៅក្នុងយន្តការកសាងប្រព័ន្ធច្បាប់របស់យើង សម្រាប់ទាំងអស់គ្នា។

### *ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

បញ្ហារបស់យើងបច្ចុប្បន្ន គឺប្រព័ន្ធច្បាប់របស់យើងនៅមានភាពចម្រុះពណ៌ ហើយមានលក្ខណៈមិនសូវច្បាស់លាស់អំពីគោលការណ៍សំខាន់ៗ ចាប់ពីច្បាប់ដល់អនុក្រឹត្យ ហើយរហូតទៅដល់ប្រកាស និងចាប់តាំងពីដំណាក់កាលនៃការតាក់តែង រហូតដល់ដំណាក់កាលនៃការអនុវត្ត ជាពិសេសខ្វះខាតយន្តការត្រួតពិនិត្យ ឬ ប្រតិតុល្យកម្ម (Check and Balance) ដូចមានអនុវត្តក្នុងប្រទេសជឿនលឿនមួយចំនួន។ ដូចនេះគួរដល់ពេលត្រូវចាប់ផ្តើមពិនិត្យមើលឡើងវិញជាប្រព័ន្ធ។ ទិដ្ឋភាពធំៗរបស់យើងក្នុងការរៀបចំច្បាប់ គឺមានការតាក់តែង ការប្រឹក្សាពិនិត្យ ការអនុម័ត ការអនុវត្ត និងការតាមដាននៃការអនុវត្ត ហើយក៏ត្រូវមានទិដ្ឋភាព (Dimension) ថ្មីមួយទៀត គឺការធ្វើវិសោធនកម្មឬរៀបចំធ្វើច្បាប់ថ្មីតែម្តង នៅពេលច្បាប់ទាំងនោះអនុវត្តមិនមានប្រសិទ្ធភាព ហួសសម័យ ឬ មិនសមស្របនឹងបរិការណ៍កម្ពុជា។

ហេតុនេះ គោលការណ៍រួមនៃការរៀបចំតាក់តែងច្បាប់ គួរត្រូវបានគិតគូរនិងរៀបចំឡើងវិញ ឱ្យទៅជានិម្មាបនកម្ម(Architecture) និងផែនទីចង្អុលផ្លូវ(Road map) សម្រាប់ការរៀបចំបង្កើតច្បាប់ ដោយក្នុងនោះគួរគិតគូឱ្យបានគ្រប់ជ្រុងជ្រោយទាំងផ្នែកទស្សនៈនីតិរដ្ឋ ទាំងផ្នែកទស្សនៈសីលធម៌ វប្បធម៌ ប្រពៃណី ចាប់តាំងពីដំណាក់កាលដំបូងរហូតដល់ដំណាក់កាលបញ្ចប់។ យើងគួរធ្វើការបែងចែករវាងច្បាប់ដែលត្រូវបង្កើតថ្មីនិងច្បាប់ដែលនៅជាធរមានស្រាប់ ដើម្បីជាមូលដ្ឋានក្នុងការធ្វើវិសោធនកម្មឬរៀបចំធ្វើថ្មី ឱ្យស្របតាមគោលការណ៍ថ្មីនេះ និងដើម្បីធានាបានថា ច្បាប់នោះមានប្រសិទ្ធភាព គុណភាព សន្តិសុខគតិយុត្ត, ចីរភាព យុត្តិធម៌សង្គម ហើយឆ្លើយតបនឹងតម្រូវការរបស់សង្គម ព្រមទាំងបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចនិងលើកកម្ពស់ជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។

នៅក្នុងយន្តការ/ក្របខ័ណ្ឌតាក់តែងច្បាប់ ត្រូវមានវិធាន (Rule) នៃការតាក់តែង(គោលការណ៍) ដើម្បីកំណត់បញ្ហា ឬសគល់នៃបញ្ហា គោលបំណង និងគោលដៅដែលចង់បាន ដោយរួមទាំងមគ្គុទេសក៍សិល្ប៍សាស្ត្រនីតិកម្ម (Guide Légistique)។ តែក៏ត្រូវគិតគូរផងដែរ ដល់ជម្រើសផ្សេងៗ ក្រៅពីការធ្វើច្បាប់ ឬ លិខិតបទដ្ឋាន ដូចជាវិធានការអប់រំណែនាំ វិធានការសេដ្ឋកិច្ច និងវិធានការផ្សេងៗទៀតដែលមិនមានជាលិខិតបទដ្ឋានជាដើម ហើយក្នុងករណីជ្រើសយកជម្រើសវិធានការច្បាប់ គឺត្រូវតែសិក្សាឱ្យបានច្បាស់អំពីផលប៉ះពាល់នៃវិធានការនោះទៅលើសង្គម សេដ្ឋកិច្ច ធុរកិច្ច និងបុគ្គល។ នៅក្នុងយន្តការអនុវត្តច្បាប់ ត្រូវមាននិយាមនីតិវិធីប្រតិបត្តិ (SOP) សម្រាប់អ្នកអនុវត្តច្បាប់ កំណត់អ្នកណាជាអ្នកអនុវត្តច្បាប់ និង

អ្នកណាជាអ្នកបកស្រាយច្បាប់ និងអ្នកណាផ្សព្វផ្សាយច្បាប់។ នៅក្នុងយន្តការតាមដានការអនុវត្តច្បាប់ ត្រូវកំណត់អ្នកណាជាអ្នកតាមដានការអនុវត្ត អ្នកវាយតម្លៃ ការអនុវត្ត/ប្រសិទ្ធភាពនៃការអនុវត្ត។ នៅក្នុងយន្តការវិសោធនកម្ម បើរកឃើញបញ្ហាប្រឈម តើត្រូវដោះស្រាយយ៉ាងម៉េច? តើច្បាប់មានស្រាប់ត្រូវវិសោធនកម្ម ឬត្រូវបង្កើតច្បាប់បន្ថែម ដើម្បីឆ្លើយតបតម្រូវការសង្គមនិងជីវភាពមនុស្ស។ នៅក្នុងយន្តការផ្សព្វផ្សាយ តើអ្នកណាខ្លះជាអ្នកផ្សព្វផ្សាយ និងយន្តការអនុវត្ត តាមកម្រិតក្រសួង ស្ថាប័នមានសមត្ថកិច្ច ព្រមទាំងការចុះផ្សាយក្នុងរាជកិច្ច។ ការកសាងច្បាប់គួរត្រូវគិតគូរពីផែនការកសាងច្បាប់ គិតជាឆ្នាំ(៥ឆ្នាំម្តង ជាដើម)។ល។ ដើម្បីឱ្យប្រព័ន្ធច្បាប់មានភាពរលូន និងមានប្រសិទ្ធភាព។

ក្នុងការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ដែលមានលក្ខណៈជាច្បាប់គោល ត្រូវគិតគូរដល់គោលការណ៍រួម ដែលពាក់ព័ន្ធនឹងវិស័យច្បាប់នោះ ឧទាហរណ៍ដូចជាច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ ដែលបានកំណត់ឱ្យមានគោលការណ៍ចំនួន១០ចំណុច រួមមាន៖ **១.ភាពជាអាជ្ញា ២.ភាពជឿទុកចិត្តបាន ៣.ឯកត្តភាព ៤.សកលភាព ៥.វិសេសភាព ៦.ចីរភាព ៧.គណនេយ្យភាព ៨.ប្រសិទ្ធភាព ៩.តម្លាភាព និង ១០.សមិទ្ធកម្ម**។ កន្លងមកច្បាប់មួយចំនួនបានកំណត់អំពីគោលការណ៍រួមរួចហើយ ប៉ុន្តែក៏នៅមានច្បាប់មួយចំនួនទៀត ពុំបានកំណត់អំពីគោលការណ៍រួមនោះទេ ដែលនេះចន្លោះប្រហោង ដែលត្រូវគិតគូរឡើងវិញ។ ដូចនេះគ្រប់ច្បាប់ គួរមានចែងអំពីគោលការណ៍រួម ក្នុងនោះពិសេស ពាក់ព័ន្ធវិស័យជំនាញបច្ចេកទេស និងបច្ចេកវិទ្យា ដូចជា បញ្ញាសិប្បនិម្មិត (AI) និងឧក្រិដ្ឋកម្ម សាយប័រ(Cyber Crimes) ជាដើម។

បច្ចុប្បន្នយើងមានក្រមចំនួន៥ រួចមកហើយ រួមមាន៖ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមបរិស្ថាននិងធនធានធម្មជាតិ ដែលក្រមខ្លះគួរពិនិត្យឡើងវិញ ហើយក្រមចំនួន៤ កំពុងត្រូវបានរៀបចំធ្វើវិសោធនកម្ម ក្នុងវិស័យព្រហ្មទណ្ឌនិងវិស័យរដ្ឋប្បវេណី។ នៅមានក្រមសំខាន់យ៉ាងតិចចំនួន២ផ្សេងទៀត ដែលកម្ពុជាគួរគិតគូររៀបចំផងដែរនោះ គឺ៖ **ក្រមពាណិជ្ជកម្ម** និង **ក្រមរដ្ឋបាល**។

## *ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

គោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតនេះ នឹងក្លាយជាឧបករណ៍មគ្គុទ្ទេសក៍ដ៏សំខាន់មួយសម្រាប់គ្រប់ក្រសួង ស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាលយកទៅប្រើប្រាស់សំដៅធានាថា រាល់ច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលបានរៀបចំតាក់តែង និងប្រកាសដាក់ឱ្យអនុវត្តមានគុណភាព ប្រសិទ្ធភាព សង្គតិភាព អនុលោមភាព សាមញ្ញភាព និងចីរភាព ព្រមទាំងសន្តិសុខគតិយុត្ត ហើយក្រុមជំនាញផ្នែកនីតិកម្មរបស់ក្រសួង ស្ថាប័ន ស្គាល់ភារកិច្ចរបស់ខ្លួន ចំណេញពេលវេលា និងធានាឱ្យមានការឯកភាព ក្នុងការរៀបចំ និងកាត់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ម្យ៉ាងវិញទៀត គោលការណ៍ណែនាំនេះ ក៏ជាត្រីវិស័យមួយសម្រាប់ទីស្តីការគណៈរដ្ឋមន្ត្រីខ្លួនឯងផងដែរ ក្នុងនាមជាអ្នកត្រួតពិនិត្យ និងប្រឹក្សាច្បាប់ ដើម្បីពង្រឹងគុណភាពនិងប្រសិទ្ធភាព ក្នុងការពិនិត្យនិងផ្តល់យោបល់លើការរៀបចំ សេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលក្រសួងស្ថាប័ននានាបញ្ជូនមកឱ្យបានលឿនឆាប់រហ័ស មានសង្គតិភាព គ្រប់ជ្រុងជ្រោយ មិនលើសមិនខ្វះ លែងជាន់សមត្ថកិច្ចគ្នា បន្ថយផលប៉ះពាល់មិនល្អដល់សង្គម សេដ្ឋកិច្ច អាជីវកម្ម និងបុគ្គល និងមានភាពជាក់ស្តែងនិយម ព្រមទាំងងាយស្រួលក្នុងការអនុវត្ត។

ក្នុងទិសដៅខាងលើនេះ និងដើម្បីពង្រឹងនិងលើកកម្ពស់គោលការណ៍នីតិរដ្ឋ សន្តិសុខគតិយុត្ត ព្រមទាំងគុណភាពនិងប្រសិទ្ធភាពនៃច្បាប់ ឆ្លើយតបនឹងវឌ្ឍនភាពសេដ្ឋកិច្ចនិងសង្គម និងតម្រូវការជាអាទិភាពនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតរបស់គ្រប់ក្រសួង ស្ថាប័ន ខ្ញុំសូមផ្តល់នូវការណែនាំ និងគូសបញ្ជាក់ចំណុចមួយចំនួន ដូចខាងក្រោម៖

១- គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ត្រូវអនុវត្តតាមគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលបានដាក់ឱ្យអនុវត្តដោយអនុក្រឹត្យលេខ១៧០ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ ដើម្បីឱ្យការរៀបចំនិងការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតមានឯកភាពនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាដើម្បីធ្វើសុខដុមនីយកម្មប្រព័ន្ធរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាបាននូវឯកភាពផ្នែករដ្ឋបាល ដែលជាកត្តាមួយយ៉ាងសំខាន់នៃឯកភាពជាតិ។

២- ក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវរៀបចំសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលអំពីគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដល់ក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល។

៣- ក្នុងករណីក្រសួង ស្ថាប័ន មានចម្ងល់លើផ្នែកទម្រង់និងការរៀបចំខ្លឹមសារនៃសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត សូមស្នើសុំកិច្ចសហការពីក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបកស្រាយ ឬក៏ផ្តល់ការបំភ្លឺ ទៅតាមជាក់ស្តែង។

៤- គ្រប់ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការកសាងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលត្រូវឆ្លើយតបនឹងវឌ្ឍនភាពសេដ្ឋកិច្ចនិងសង្គម និងតាមតម្រូវការជាអាទិភាពនៃបេសកកម្មតួនាទី និងភារកិច្ចរបស់ខ្លួន។ ដោយឡែក ចំពោះសេចក្តីព្រាងច្បាប់និងសេចក្តីព្រាងព្រះរាជក្រឹត្យដែលមានលក្ខណៈជាបទបញ្ញាទូទៅ ត្រូវភ្ជាប់មកជាមួយឯកសារទស្សនាទានរួមមួយ ដែលបញ្ជាក់ពីតម្រូវការចាំបាច់ គោលបំណង អត្ថប្រយោជន៍ ផលប៉ះពាល់ផ្នែកសង្គម សេដ្ឋកិច្ច និងនយោបាយជាតិនិងអន្តរជាតិ រួចបញ្ជូនមកគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ដើម្បីពិនិត្យនិងសម្រេចជាមុន លើកលែងតែករណីបន្ទាន់ចាំបាច់តាមការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាល។

៥- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ត្រូវរៀបចំសេចក្តីព្រាង មគ្គុទេសក៍សិល្បសាស្ត្រនីតិកម្ម (Guide Légistique) ដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាព ព្រមទាំងលុបបំបាត់កំហុសឆ្គង (Defects) ក្នុងការតាក់តែង និងផ្តល់យោបល់លើការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត សំដៅធានាបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព សង្គតិភាព និងភាពសម ស្រប តាមការវិវត្តនៃសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា។

៦- គ្រប់ក្រសួង ស្ថាប័ន ដោយរួមទាំងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវរៀបចំកម្មវិធីពង្រឹងប្រសិទ្ធភាពនិងសមត្ថភាពលើការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត សំដៅបង្កើននូវភាពជឿជាក់និងភាពអាចប៉ាន់ស្មានបាននូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល, កាត់បន្ថយនូវភាពស្មុគស្មាញ ឬការិយាធិបតេយ្យហួសហេតុ (red-tape) ពីច្បាប់និងលិខិតបទដ្ឋាន គតិយុត្តជាធរមាន និងលើកកម្ពស់ភាពប្រកួតប្រជែង ព្រមទាំងការសម្រេចបាននូវចក្ខុវិស័យរបស់យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងក្នុងដំណើរឆ្ពោះទៅសម្រេចចក្ខុវិស័យឆ្នាំ២០៥០។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី!***

គោលការណ៍ណែនាំនេះ គឺជាឯកសាររស់ដែលអាចធ្វើការកែសម្រួលនិងបំពេញបន្ថែម នាពេលខាងមុខ ស្របតាមស្ថានភាពជាក់ស្តែងតាមការចាំបាច់។ ម្យ៉ាងវិញទៀត ទោះបីគោលការណ៍ណែនាំថ្មីនេះមានគំរូទម្រង់ច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតរហូតទៅដល់ ៧៣ គំរូទម្រង់ ធៀបនឹងគោលការណ៍ណែនាំចាស់មានត្រឹមតែចំនួន ៤២ គំរូទម្រង់ក្តី តែខ្ញុំនៅតែយល់ថា មិនទាន់គ្រប់គ្រាន់នៅឡើយ ព្រោះគំរូទម្រង់ទាំងនេះជាគោលគំនិតទូទៅសម្រាប់យកទៅអនុវត្តជាក់ស្តែង ដោយមិនទាន់គិតទៅដល់ការវិវត្តយ៉ាងឆាប់រហ័សនៃវិស័យឌីជីថល។ ក្នុងន័យនេះ ខ្ញុំសូមលើកទឹកចិត្តដល់ក្រសួង ស្ថាប័នទាំងអស់ សូមផ្តល់នូវមតិត្រឡប់ (Feedback) ឬក៏ការស្នើសុំកែសម្រួល និងបំពេញបន្ថែមផ្សេងៗ ក្រោយពីបានយកទៅអនុវត្តជាក់ស្តែង ដើម្បីបន្តធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំនេះឱ្យកាន់តែពេញលេញគ្រប់ជ្រុងជ្រោយ ស្របតាមស្ថានភាពរីកចម្រើនឈានឡើងរបស់សង្គមជាតិយើង។

មុននឹងបញ្ចប់ ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះសម្តែងនូវអំណរគុណនិងកោតសរសើរដល់ថ្នាក់ដឹកនាំនៃទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអ្នកច្បាប់ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គម និងវប្បធម៌ ព្រមទាំងមន្ត្រីរាជការទាំងអស់ ដែលបានខិតខំប្រឹងប្រែងរៀបចំកែសម្រួលគោលការណ៍ណែនាំថ្មីនេះទទួលបានផ្លែផ្កា។ ខ្ញុំក៏សូមវាយតម្លៃខ្ពស់ចំពោះ ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលកន្លងមកបានអនុវត្តតាមគោលការណ៍ណែនាំឆ្នាំ២០១៣ ក្នុងការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតរបស់រាជរដ្ឋាភិបាលប្រកបដោយ គុណភាព ប្រសិទ្ធភាព សង្គតិភាព អនុលោមភាព សាមញ្ញភាព និងចីរភាព ព្រមទាំងមានសន្តិសុខគតិយុត្ត។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី បានសមប្រកបដោយសុខភាពល្អ និងទទួលបានជោគជ័យក្នុងគ្រប់ភារកិច្ចរៀងៗខ្លួន ព្រមជាមួយនឹងសេចក្តីចម្រើនក្រោមម្លប់ដ៏ត្រជាក់នៃសុខ សន្តិភាព និងជួបប្រទះនូវពុទ្ធពរទាំង៤ប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**